ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី

ខុទ្ទកាល័យ

# សេចក្តីថ្លែងការណ៍

ម្តងហើយម្តងទៀត ទីភ្នាក់ងារសារព័ត៌មាន PHNOM PENH POST ដែលជាកាសែតគ្មានអព្យាក្រឹត្យនិងគ្មានសីលធម៌ជាអ្នកកាសែត តែងតែផ្តៀតនិកាសបំភ្លៃ មួលបង្កាច់បង្កហេតុមកលើថ្នាក់ដឹកនាំ និងមន្ត្រីរាជរដ្ឋាភិបាល ។

កាលនៅស្រុកឆែប ខេត្តព្រះវិហារ សម្តេចអគ្គមហាសេនាបតីតេជោ បានមានប្រសាសន៍ថា "...................មើលងាយណាស់ មកស្ទរ ហ៊ុន សែន ! អធិរាជ Facebook ! " ។ ពាក្យថា " អធិរាជFacebook " សំដៅទៅលើអ្នកល្ងង់ដែលចោទថា មានការលួច ឬបន្លំ LIKES នៅក្នុងFacebook បាន សម្តេចពុំបានមានប្រសាសន៍ថា "មើលងាយណាស់មកស្ទរខ្ញុំ ដែលជាអធិរាជFacebook " នោះទេ តែអ្នកចាំតែរករឿង បានចាប់ចំណុចនេះយកទៅកាឡៃដោយមិនចេះខ្មាស់អៀន ថា "លោក ហ៊ុន សែន ប្រកាសខ្លួនឯងជាអធិរាជ Facebook " ។

ខុទ្ទកាល័យសូមរំលឹកថា កាលពីឆ្នាំ ២០១៥ សារពត៌មាន PHNOM PENH POST បានមួលបង្កាច់ដីកាបញ្ជូនមួយច្បាប់របស់ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី ទៅជាបញ្ហាមួយទៅឲ្យស្ថាប័នពាក់ព័ន្ធដោះស្រាយបញ្ហាមួយដោយលំអៀងម្តងរួចមកហើយ។

នៅចំពោះមុខអំពើបែបនេះ ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ មានការសោកស្តាយណាស់ដោយឃើញស្ថាប័នឯកពជ្យបរទេសមួយបន្ថោកតម្លៃខ្លួនឯងដល់ថ្នាក់នេះ។

ខុទ្ទកាល័យមានការសោកស្តាយដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើយុទ្ធនាការអក្ខរកម្មយ៉ាងគគ្រឹកគគ្រេង តែនៅតែមានមនុស្សតាំងខ្លួនធ្វើល្ងង់។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០១៦
**នាយកខុទ្ទកាល័យ**

ហ៊ុ_សិទ្ធី